# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តហ្វ្រង់ស្វ័រសាវីយេ
# ចំប៉ា ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០

## ឈើឆ្កាងយាងមកដើម្បីសង្គ្រោះយើង

**អត្ថបទទី១៖ អេសេគីអែល ៣៧,១២-១៤**

យើងនឹងបើកផ្នូររបស់អ្នករាល់គ្នា ហើយនាំអ្នករាល់គ្នាឡើងពីផ្នូរនោះ។ អគ ៣៧,១២

**អត្ថបទទី២៖ រ៉ូម ៨,៨-១១**

ប្រសិនបើព្រះគ្រីស្តគង់នៅក្នុងបងប្អូន ទោះបីរូបកាយរបស់បងប្អូនស្លាប់ ព្រោះតែបាបក៏ដោយ ក៏ព្រះវិញ្ញាណនៅតែផ្តល់ជីវិតឲ្យបងប្អូនដែរ។ រម ៨,១០

**ដំណឹងល្អ៖ យ៉ូហាន ១១,១-៤៥**

អ្នកណាដើរនៅពេលយប់ អ្នកនោះមុខតែជំពប់ជើងដួលជាមិនខាន ព្រោះគេគ្មានពន្លឺនៅក្នុងខ្លួនទេ។ យហ ១១,១០

បងប្អូនជាទីស្រឡាញ់!

នៅក្នុងអត្ថបទដែលយើងស្តាប់ថ្ងៃនេះ អំពីរឿងលោកឡាសា ណែនាំឲ្យយើងអាចរិះគិតពិចារណាថែមទៀតអំពីបរិយាកាសនៅក្នុងពិភពលោករបស់យើងបច្ចុប្បន្ននេះ។ នៅពេលនោះព្រះយេស៊ូបានជ្រាបដំណឹងមួយ គឺឡាសាដែលជាមិត្តសម្លាញ់របស់ព្រះអង្គកំពុងឈឺធ្ងន់។ ព្រះយេស៊ូមានព្រះបន្ទូលថា "**ជំងឺនេះកើតឡើងមិនមែនឲ្យគាត់បាត់បង់ជីវិតទេ គឺដើម្បីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ ព្រមទាំងឲ្យព្រះបុត្រារបស់ព្រះអង្គសម្តែងសិរីរុងរឿងវិញ**"។ នៅពេលនោះព្រះយេស៊ូមិនទាន់បានទៅដល់កន្លែងលោកឡាសាទេ គឺព្រះអង្គបានបន្តបេសកកម្មរបស់ព្រះអង្គតែពីរថ្ងៃក្រោយមកទើបព្រះអង្គបានធ្វើដំណើរដល់កន្លែងលោកឡាសា។ ព្រះអង្គមានព្រះបន្ទូលថា "**ក្នុងមួយថ្ងៃមាន២៤ម៉ោង អ្នកណាដើរនៅពេលថ្ងៃអ្នកនោះមិនជំពប់ជើងដួលឡើយ ព្រោះគេមានពន្លឺរបស់ពិភពលោកនេះ ផ្ទុយទៅវិញអ្នកណាដើរនៅពេលយប់អ្នកនោះមុខតែនឹងជំពប់ជើងដួលជាមិនខាន ព្រោះគេគ្មានពន្លឺនៅក្នុងខ្លួនគេ**"។ អ្វីដែលយើងបានស្តាប់ ជំងឺនេះកើតឡើងដើម្បីបង្ហាញសិរីរុងរឿងរបស់ព្រះជាម្ចាស់ ពេលវេលារបស់យើងដែលមាន២៤ម៉ោងមាន១២ម៉ោងនៅក្នុងពន្លឺនិង១២ម៉ោងនៅក្នុងភាពងងឹត។ ប្រសិនបើ យើងសុខចិត្តដើរក្នុងពេលវេលា១២ម៉ោងពេលថ្ងៃ យើងដឹងថាយើងដើរនៅក្នុងពន្លឺណែនាំឲ្យយើងមិនដួលទេ ប្រសិនបើយើងសុខចិត្តដើរនៅពេលយប់ដែលគ្មានពន្លឺណែនាំឲ្យយើងដួល។

បងប្អូនជាទីស្រឡាញ់ នៅក្នុងពិភពលោកទាំងមូលក្នុងពេលវេលាដែលមានជំងឺកូវីដ១៩កើតឡើងស្ទើរគ្រប់ប្រទេស ណែនាំឲ្យយើងត្រូវតែមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់។ នៅតាម

ប្រទេសនីមួយៗ គឺបានចាប់ផ្ដើមដោយអ្នកជំងឺម្នាក់ក្រោយមកចម្លងដល់មនុស្សជាច្រើន នៅប្រទេសចិនពីម្នាក់ឡើងដល់ជាង១០ម៉ឺននាក់ នៅអាមេរិកពីម្នាក់ឡើងដល់ជាង១០ម៉ឺននាក់ នៅអឺរ៉ុបពីម្នាក់ឡើងដល់ជាង៣០ម៉ឺននាក់។ ដូច្នេះ នៅតាមភូមិយើងដែលរស់នៅមានផ្ទះជិតៗគ្នា នៅក្នុងភូមិដែលមានកន្លែងតូច ដែលយើងបន្តសកម្មភាពធម្មតាប្រចាំថ្ងៃ ឲ្យយើងការពារថែរក្សាសុខភាពរបស់យើងរៀងៗខ្លួនឲ្យបានល្អ។ **តើជំងឺនេះ កើតឡើងដើម្បីសម្ដែងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដូចជំងឺលោកឡាសាឬទេ?** ជំងឺបានណែនាំឲ្យលោកឡាសាស្លាប់ ណែនាំឲ្យព្រះយេស៊ូបានយំសោក នៅពេលឃើញមិត្តសម្លាញ់របស់ព្រះអង្គបានទទួលមរណភាព។ ប៉ុន្តែ បានណែនាំឲ្យព្រះយេស៊ូបង្ហាញឫទ្ធានុភាពរបស់ព្រះបិតា ដោយបានទូលអង្វរព្រះបិតាថាសូមប្រស់ជីវិតឲ្យលោកឡាសា សាជាថ្មី។ នៅពេលនោះ លោកឡាសាបានចេញពីផ្នូរទាំងមានជីវិតដែលព្រះយេស៊ូប្រទាននៅលើផែនដីនេះ។

ពីរខែកន្លងមក យើងបានឃើញមនុស្សដែលស្លាប់ដោយសារជំងឺកូវីដ១៩ប្រហែល២ម៉ឺននាក់ នៅទូទាំងពិភពលោក។ នេះជាចំនួនមួយច្រើននៅក្នុងរយៈពេលខ្លី មេរោគនេះប្លែកដោយបានធ្វើឲ្យឆ្លងលឿននិងស្លាប់ក្នុងពេលវេលាខ្លី។ **តើជំងឺនេះ កើតឡើងដើម្បីសម្ដែងសិរីរុងរឿងរបស់ព្រះជាម្ចាស់ឬទេ?** ប្រហែលមិនមែនជាពេលវេលា ដើម្បីគិតដល់សិរីរុងរឿងរបស់ព្រះជាម្ចាស់។ ប៉ុន្តែ ខ្ញុំគិតថាជាពេលវេលាដើម្បីគិតដែរ ព្រោះយើងកំពុងធ្វើដំណើរជាមួយព្រះយេស៊ូ នៅក្នុង៤០ថ្ងៃព្រះយេស៊ូបានចូលរងទុក្ខលំបាក។ សប្ដាហ៍ក្រោយយើងធ្វើបុណ្យហែស្លឹក និងចូលនៅក្នុងសប្ដាហ៍ពិសិដ្ឋដែលព្រះយេស៊ូជប់លៀងចុងក្រោយជាមួយក្រុមសាវ័ក ហើយគេចាប់ព្រះយេស៊ូឆ្កាង ព្រះយេស៊ូសោយទិវង្គតនិងគេយកព្រះសពព្រះអង្គទៅបញ្ចុះក្នុងរូងថ្ម។ ក្រោយមកយើងចូលនៅក្នុងភាពស្ងៀមស្ងាត់ រហូតដល់ពេលវេលាយើងឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ដូច្នេះ ដំណាក់កាលដែលកើតឡើងនៅក្នុងជីវិតរបស់ព្រះយេស៊ូផ្ទាល់ ជាដំណាក់កាលដែលយើងឃើញនៅក្នុងជីវិតនៃពិភពលោកសព្វថ្ងៃ។ សព្វថ្ងៃ ពិភពលោករស់នៅក្នុងភាពងងឹតនិងការភ័យខ្លាច សព្វថ្ងៃជាពេលវេលាត្រូវភ្ញាក់ស្មារតីដើម្បីជួយគ្នាទៅវិញទៅមក។ យើងមានគ្រូពេទ្យ និងក្រុមការងារនៅតាមមន្ទីរពេទ្យដែលបានតស៊ូអស់ពីសមត្ថភាព មានបងប្អូនមួយចំនួនបានខិតខំជួយគ្នាទៅវិញទៅមក ដើម្បីជួយអ្នកជំងឺ ដើម្បីលើកទឹកចិត្ត ដើម្បីធ្វើដំណើរជាមួយបងប្អូនដែលមានជំងឺ ដើម្បីអប់រំបងប្អូនដែលមិនទាន់មានជំងឺឲ្យចេះការពារថែរក្សាសុខភាព។ នេះជាពេលវេលា ដែលយើងរស់នៅក្នុងទុក្ខលំបាករបស់ព្រះយេស៊ូ យើងអាចនិយាយថាសប្ដាហ៍ពិសិដ្ឋដែលយើងនឹងប្រារព្ធ ទៅជាសប្ដាហ៍ពិសិដ្ឋដ៏វែងឆ្ងាយសម្រាប់ប្រទេសនីមួយៗ ដែល

ត្រូវបិទទ្វារព្រំដែនកុំឲ្យអ្នកខាងក្រៅចូល បិទទ្វារនៅក្នុងប្រទេសកុំឲ្យប្រជាជនចេញពីផ្ទះ ដើម្បីបង្ការការឆ្លងជំងឺនេះ។

នៅប្រទេសកម្ពុជា ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង១១និង៥៩នាទីយប់នេះ រដ្ឋាភិបាលបានសម្រេចបិទទ្វារប្រទេសទាំងស្រុង ដោយមិនអនុញ្ញាតឲ្យជនបរទេសណាម្នាក់ចូលពីក្រៅ លុះត្រាតែមានលក្ខខណ្ឌពិសេស។ នេះជាដំណាក់កាលទីមួយ យើងចាំមើលបន្តិចទៀតតើយើងមានសិទ្ធិធ្វើអ្វីខ្លះ? ប៉ុន្តែ យើងដឹងថាពិភពលោកទាំងមូលរួមជាមួយព្រះយេស៊ូ យើងចូលនៅក្នុងទុក្ខលំបាករបស់ព្រះអង្គយ៉ាងជាក់ស្តែង។ ដូច្នេះ ពេលវេលានេះជាពេលវេលាដើម្បីជម្រះចិត្តគំនិតរបស់យើង ជាពេលវេលាដើម្បីឲ្យយើងភ្ញាក់ស្មារតីអំពីអ្វីដែលមានសារសំខាន់បំផុតនៅក្នុងជីវិត។ អ្វីដែលជាសារសំខាន់បំផុតនៅក្នុងជីវិត គឺម្ហូបអាហារ គឺសេវាកម្មសុខភាព គឺក្រុមគ្រួសារដែលជាកម្លាំងជាសេចក្តីស្រឡាញ់សម្រាប់បុគ្គលម្នាក់ៗ។ នេះជាអ្វីដែលយើងខ្វះ មានន័យថានៅពេលយើងខ្វះយើងមើលឃើញអ្វីដែលសំខាន់សម្រាប់ជីវិតយើង។ ដូច្នេះ សូមបងប្អូនយល់ថាជីវិតជាគ្រួសារជាអាទិភាពសម្រាប់យើង ហើយម្ហូបអាហារនិងសុខភាពក៏ជាអាទិភាពសម្រាប់ជីវិតរបស់យើងដែរ។ ប៉ុន្តែ សម្រាប់យើងដែលជាគ្រីស្តបរិស័ទនេះជាពេលវេលា ដើម្បីសម្លឹងមើលព្រះយេស៊ូនៅលើឈើឆ្កាង សម្លឹងមើលព្រះយេស៊ូដែលបានសោយទិវង្គតដើម្បីរំដោះបាបយើង។

នៅពេលខ្ញុំដើរដើម្បីប្រោះទឹកព្រះពរដល់គ្រួសារនីមួយៗក្នុងភូមិ ដោយដឹងថានេះជាព្រះយេស៊ូដែលបានចូលនៅក្នុងផ្ទះបងប្អូន ដើម្បីប្រទានពរប្រទានកម្លាំងនិងប្រទានជំនឿថែមទៀត។ យើងដឹងថា ឈើឆ្កាងយាងមកដើម្បីសង្គ្រោះយើង ពីរថ្ងៃមុនសម្តេចប៉ាបបានអធិដ្ឋានពិសេសនៅមុខឈើឆ្កាង ដែលនៅឆ្នាំ១៥២២នៅទីក្រុងរ៉ូមមានជំងឺប៉េសបានសម្លាប់មនុស្សជាច្រើន។ ពេលនោះ គ្រីស្តបរិស័ទនិងលោកបូជាចារ្យបានយកឈើឆ្កាងនេះ ហែជុំវិញទីក្រុងរ៉ូមអស់រយៈពេល ១៦ថ្ងៃ ដើម្បីសុំឲ្យព្រះយេស៊ូនៅលើឈើឆ្កាងប្រទានពរ និងសង្គ្រោះប្រជាជនទីក្រុងរ៉ូមទាំងអស់ពិតមែនជំងឺប៉េសបានឈប់សម្លាប់មនុស្ស។ ឈើឆ្កាងនេះ គេបានថែរក្សារហូតមកដល់សព្វថ្ងៃពេលមានឆ្នាំមហាករុណាទិគុណព្រះសហគមន៍បានយកឈើឆ្កាងនេះចេញពីព្រះវិហារសន្តម៉ាសែលនៅទីក្រុងរ៉ូម។ កាលពីយប់ថ្ងៃសុក្រ សម្តេចប៉ាបបានយកឈើឆ្កាងនេះដើម្បីអធិដ្ឋានសម្រាប់ពិភពលោកទាំងមូល ដោយជឿថាព្រះឈើឆ្កាងរបស់ព្រះយេស៊ូគ្រីស្តមានឫទ្ធានុភាពដើម្បីសង្គ្រោះមនុស្សលោក។

បងប្អូនជាទីស្រឡាញ់ នៅតាមផ្ទះនីមួយៗសូមបងប្អូនរៀបចំតុអាសនៈតូចមួយ ឲ្យយើងមានឈើឆ្កាងនៅក្នុងផ្ទះរបស់យើង។ សូមបងប្អូនអុជទៀនធូបរាល់ថ្ងៃ ដើម្បីថ្វាយទៅព្រះជា

ម្ចាស់នូវជីវិតយើង គ្រួសារយើង ភូមិយើង ប្រទេសយើង ពិភពលោកយើង ដោយដឹងថាមានតែឫទ្ធានុភាពនៃព្រះឈើឆ្កាងដែលអាចសង្គ្រោះមនុស្សលោកបាន។ យើងបានស្តាប់ ព្រះយេស៊ូណែនាំឲ្យមនុស្សស្លាប់រស់ឡើងវិញ ព្រះយេស៊ូណែនាំឲ្យមនុស្សស្លាប់មានជីវិតអស់កល្បជានិច្ច "**អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយក៏នឹងបានរស់ជាមិនខាន**"។ យើងមានមនុស្សយ៉ាងច្រើនដែលបានទទួលមរណភាពហើយ យើងជឿថាព្រះជាម្ចាស់នឹងទទួលពួកគេនៅស្ថានបរមសុខ។ នៅពេលនេះ ជាពេលវេលាមួយសម្រាប់យើងជាគ្រីស្តបរិស័ទ ដើម្បីប្រកាសយ៉ាងឱឡារិករួមជាមួយនាងម៉ាថា ថា "**បពិត្រព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿថាព្រះអង្គពិតជាព្រះគ្រីស្ត ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយពិតជាព្រះអង្គដែលត្រូវយាងមកនៅក្នុងពិភពលោកនេះមែន**" ពិតមែនព្រះគ្រីស្តយាងមកដើម្បីសង្គ្រោះយើង ព្រះគ្រីស្តយាងមកដើម្បីប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ។ អាម៉ែន៕